# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជានៅជុនបូស្កូទឹកថ្លា
# ថ្ងៃទី២១ កក្កដា ២០១៧

អត្ថបទទី១៖សរ ១១,១០-១៤
ដំណឹងល្អ៖មថ ១២,១-៨

បងប្អូនជាទីស្រឡាញ់!

សព្វថ្ងៃនៅភ្នំពេញ មានគេសាងសង់អាគារថ្មីៗជាច្រើន នៅមុខការដ្ឋានយើងឃើញមានគេសរសេរសុវត្ថភាពជាចំបង។ ប៉ុន្តែសម្រាប់យើងជាគ្រីស្តបរិស័ទ យើងត្រូវយកសក្ខីភាពជាចំបង ដើម្បីឲ្យយើងគិតអំពីទ្រព្យសម្បត្តិដែលយើងបានទទួលតាមរយៈព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ធ្វើដូចម្តេច ដើម្បីផ្តល់សក្ខីភាពអំពីជីវិតដែលយើងបានទទួលពីព្រះយេស៊ូ ធ្វើដូចម្តេចដើម្បីផ្តល់សក្ខីភាពអំពីសេចក្តីស្រឡាញ់ដែលយើងបានទទួល។ ប្អូនដែលបានរៀននៅសាលាដុនបូស្កូកន្លងមក យើងបានទទួលទ្រព្យសម្បត្តិយ៉ាងច្រើន នៅក្នុងរបៀបដែលចេះស្រឡាញ់គ្នា គោរពគ្នា រួមរស់ជាមួយគ្នា រៀបចំអនាគត់ផ្ទាល់ខ្លួន ដោយមានចិត្តស្មោះត្រង់ ដោយមានសេរីភាពនៅក្នុងខ្លួន ដោយយកចិត្តទុកដាក់ ដោយខិតខំរៀនសូត្រ ខិតខំអនុវត្តអ្វីដែលយើងបានរៀន ដូច្នេះយើងបានទទួលទ្រព្យសម្បត្តិច្រើនដែលយើងអាចចែករំលែកជាមួយបងប្អូនឯទៀតៗ។

ដើម្បីផ្តល់សក្ខីភាពអំពីជីវិត ដើម្បីផ្តល់សក្ខីភាពអំពីសេចក្តីស្រឡាញ់ សន្តប៉ូលបានគិតអស់ហើយដើម្បីទៅជាសាក្សីនៃព្រះជាម្ចាស់។

ទីមួយ អាវពន្លឺ គឺយកជំនឿធ្វើជាខែល សម័យសន្តប៉ូលមានសង្គ្រាមច្រើន ដូច្នេះដើម្បីការពារទាហានគេមានខែល។ ដំបូងយើងត្រូវការទទួលជំនឿនៅលើព្រះគ្រីស្ត ដើម្បីធ្វើជាពន្លឺមួយ នៅថ្ងៃយើងទទួលអគ្គសញ្ញាជ្រមុជទឹកយើងបានបំពាក់ព្រះយេស៊ូ ដោយបំពាក់អាវមួយដែលយើងមើលមិនឃើញ ប៉ុន្តែនៅជាប់ជាមួយយើងអស់មួយជីវិត។ ព្រះយេស៊ូបានអញ្ជើញយើង ឲ្យយើងធ្វើជាពន្លឺសម្រាប់បងប្អូនឯទៀតៗ ដោយសារជំនឿដែលយើងបានទទួល ដោយសារសេចក្តីស្រឡាញ់ដែលយើងបានទទួល ដោយសារគ្រប់ទ្រព្យសម្បត្តិដែលយើងបានទទួលនៅក្នុងជីវិត។

ទីពីរ ខ្សែក្រវ៉ាត់ គឺព្រះបន្ទូលរបស់ព្រះជាម្ចាស់ជាសេចក្តីពិត នៅក្នុងអត្ថបទទីមួយថ្ងៃនេះនិយាយថា **ព្រះបន្ទូលរបស់ព្រះជាម្ចាស់ជាសេចក្តីពិត** សន្តប៉ូលនិយាយថា ចូរយកសេចក្តីពិតមកក្រវ៉ាត់ចង្កេះ។ សេចក្តីពិត ជាជីវិតរបស់យើង ប្រសិនបើយើងជាមនុស្សដែលគ្មានចិត្តស្មោះ យើងមិនអាចកសាងទំនាក់ទំនងនៅក្នុងសង្គមបានទេ ហើយយើងមិនអាចកសាងសង្គមដែលមានយុត្តិធម៌ពិតៗបានឡើយ។ តើយើងជាអ្នកដែលយកសេចក្តីពិតមកក្រវ៉ាត់ចង្កេះយើងហើយឬនៅ? ជាខ្សែដែលការពារយើង ឲ្យយើងរស់នៅក្នុងសេចក្តីពិតជានិច្ច។ នៅក្នុងគម្ពីរ ព្រះយេស៊ូបានណែនាំឲ្យយើងទៅជាមនុស្សប្លែកមែនទែន ដោយសារព្រះយេស៊ូឲ្យយើងស្រឡាញ់សត្រូវ ដើម្បីឲ្យយើងរស់នៅតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែលទៅជាសេចក្តីពិត ដើម្បីឲ្យយើងរស់នៅដោយមានចិត្តស្មោះនៅក្នុងសង្គមនិងក្នុងក្រុមគ្រួសារយើង។

ទីបី មួកការពារ គឺអធិដ្ឋានជានិច្ច ប្រសិនបើយើងរស់នៅក្នុងបរិយាកាសរបស់ព្រះជាម្ចាស់។ ពិតមែនយើងមើលមិនឃើញបរិយាកាសនេះ ប៉ុន្តែបើយើងយកព្រះជាម្ចាស់ជាទីពឹង បើយើងយកព្រះបន្ទូលរបស់ព្រះជាម្ចាស់ជាទីពឹង បើយើងរស់នៅក្នុងការអធិដ្ឋានដោយដឹងថាព្រះជាម្ចាស់គង់នៅជាមួយយើងជានិច្ច ព្រះជាម្ចាស់បីដូចជាមួកការពារយើងដែលយើងមើលមិនឃើញ ប៉ុន្តែយើងដឹងថាយើងលែងខ្លាចអ្វីទាំងអស់។ ដើម្បីឲ្យព្រះជាម្ចាស់គង់នៅជាមួយយើង ឲ្យយើងយកចិត្តទុកដាក់អធិដ្ឋាន ដូចសន្តប៉ូលបាននិយាយថា ចូរអធិដ្ឋានគ្រប់ពេលវេលា។

ទីបួន ស្បែកជើង គឺលើកលែងទោស ដើម្បីមើលអ្នកដទៃមិនមែនជាសត្រូវរបស់យើង ប៉ុន្តែទោះបីគេធ្វើខុសយើងត្រូវការលើកលែងទោសឲ្យគេ។ ទោះបីយើងមានបញ្ហាអ្វីនឹងគ្នា យើងត្រូវតែលើកលែងទោសឲ្យគ្នាទៅវិញទៅមក តាមការណែនាំរបស់ព្រះយេស៊ូ ដូចសន្តប៉ូលនិយាយថា ព្រះអម្ចាស់បែរព្រះភ័ក្ត្រទតមកលោកសិលា។

ទីប្រាំ ស្រោមដៃ គឺសេចក្តីស្រឡាញ់ ដោយដៃរបស់យើងយើងអាចផ្តល់សក្ខីភាពអំពីសេចក្តីស្រឡាញ់ច្រើន។ ជីវិតរបស់យើងជាគ្រីស្តបរិស័ទ គឺអនុវត្តតាមព្រះបន្ទូលរបស់ព្រះយេស៊ូ គឺត្រូវស្រឡាញ់គ្នាទៅវិញទៅមក ដូចខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ។ ធ្វើដូចម្តេច ដើម្បីស្រឡាញ់តាមរបៀបរបស់ព្រះយេស៊ូ ដែលបានលើកលែងទោសឲ្យអ្នកដែល

សម្លាប់ព្រះអង្គ ដោយសារសេចក្ដីស្រឡាញ់ណែនាំឲ្យយើងអាចបង្កើតសុខសន្តិភាព។ អ្នកម្ដាយតេរេសាបាននិយាយថា ស្ងៀមស្ងាត់ណែនាំឲ្យយើងអធិដ្ឋាន អធិដ្ឋានណែនាំឲ្យយើងមានជំនឿ ជំនឿណែនាំឲ្យយើងមានសេចក្ដីស្រឡាញ់ សេចក្ដីស្រឡាញ់ណែនាំឲ្យយើងបម្រើ បម្រើណែនាំឲ្យយើងកសាងសុខសន្តិភាពបាន។ ដូច្នេះ សេចក្ដីស្រឡាញ់ជាប្រភពសុខសន្តិភាព។ ហេតុនេះហើយឲ្យយើងពាក់ស្រោមដៃនៃសេចក្ដីស្រឡាញ់ ដែលណែនាំឲ្យយើងអាចបង្ហាញសេចក្ដីស្រឡាញ់ដល់បងប្អូនឯទៀតៗ។

ទីប្រាំមួយ ស្បែកជើង គឺសេចក្ដីក្លាហាន ដោយយកចិត្តប្រុងប្រៀបផ្សាយដំណឹងល្អអំពីសេចក្ដីសុខសាន្ដ មកពាក់ជាស្បែកជើង ដើម្បីមានសេចក្ដីក្លាហាន ដើម្បីដើរគ្រប់ទីកន្លែងដើម្បីកសាងសុខសន្តិភាព និងដើម្បីឲ្យយើងប្រកាសដំណឹងល្អអំពីសេចក្ដីសុខសាន្ដ។

ដូច្នេះ យូរៗម្ដងឲ្យយើងនឹកឃើញថា យើធ្វើជាពន្លឺសម្រាប់បងប្អូនឯទៀតៗ យើងប្រើខ្សែក្រវ៉ាត់នៃសេចក្ដីពិត ឲ្យយើងរស់នៅក្នុងបរិយាកាសរួមជាមួយព្រះជាម្ចាស់ដើម្បីអធិដ្ឋាន ឲ្យភ្នែកតារបស់យើងមើលគេជាមិត្តមិនមែនជាសត្រូវ ដោយលើកលែងទោសគ្រប់ពេលវេលា ឲ្យដៃរបស់យើងសម្ដែងសេចក្ដីស្រឡាញ់គ្រប់ពេលវេលា និងឲ្យយើងមានសេចក្ដីក្លាហានពេញខ្លួន ដើម្បីដើរនៅក្នុងជីវិតដោយកសាងសុខសន្តិភាព។ ប៉ុន្តែសុខសន្តិភាពមាន លុះត្រាតែយើងពោរពេញដោយសេចក្ដីស្រឡាញ់ និងចិត្តបម្រើជានិច្ច។ អាម៉ែន៕